# សិគាលោវាទសូត្រ

សិគាលោវាទសូត្រនេះ មានទម្រង់ជារបៀបសន្ទនារវាងព្រះពុទ្ធ និងយុវជនសិគាលៈ ឬជារបៀបបុច្ឆា វិសជ្ជនាយ៉ាងពីរោះ អ្នកម្ខាងលើកនូវសំនួរ អ្នកម្ខាងទៀតឆ្លើយនូវបញ្ហាកម្ម ។

## ផ្ទៃរឿង

ដូចដែលខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ថ្ងៃមួយនោះព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់កំពុងគង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវា បស្ថាន ក្បែក្រុងរាជគ្រឹះ ។

ពេលនោះ យុវជនមួយរូបឈ្មោះសិគាលៈជាបុត្រនៃគ្រួសារមួយ តែងភ្ញាក់ពីព្រលឹមហើយចេញដើរទៅ ក្នុងក្រុងរាជគ្រឹះដោយមានសក់និងសំលៀកបំពាក់ទទឹកជោក លើកដៃទាំងពីរប្រណម្យឡើងថ្វាយបង្គំទិសទាំង ៦គឺ ទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងខាងលើ។ នៅព្រឹកថ្ងៃនោះព្រះបរមគ្រូទ្រង់យាងទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ។ ព្រះអង្គបានទតឃើញសិគាលៈកំពុងថ្វាយបង្គំទិសដូច្នេះ ទ្រង់បានមានព្រះតម្រាស់សួរថាៈ

ម្នាលយុវជន, ហេតុអ្វីបានជាអ្នកក្រោកពីព្រលឹមហើយធ្វើដំណើរចេញមកក្រុងរាជគ្រឹះមានសក់និងសំលៀកបំពាក់ទទឹកជោកហើយថ្វាយបង្គំទិសដូច្នេះ?

បពិត្រព្រះអង្គដ៏ចំរើន ឪពុកខ្ញុំព្រះអង្គមុនពេលគាត់អនិច្ចកម្ម បាននិយាយប្រាប់ខ្ញុំព្រះអង្គថាៈ ម្នាលកូនប្រុស ឯងគប្បីថ្វាយបង្គំទិសទាំង៦។ ដោយគោរពតាមបណ្តាំឪពុកខ្ញុំព្រះអង្គនោះទើបខ្ញុំព្រះអង្គក្រោកពីព្រលឹមចេញមកកាន់ក្រុងរាជគ្រឹះថ្វាយបង្គំទិសទាំងឡាយ។

ម្នាលយុវជន, ក្នុងសាសនាតថាគត គេមិនថ្វាយបង្គំទិសទាំង ៦បែបនេះទេ។

បពិត្រព្រះអង្គដ៏ចំរើន ក្នុងសាសនាព្រះអង្គនេះ តើគេថ្វាយបង្គំទិសទាំង ៦ ដូចម្តេចវិញ? សូមព្រះអង្គមេត្តាសំដែងប្រាប់ខ្ញុំព្រះអង្គផង។

បើដូច្នេះ យុវជន ចូរអ្នកប្រឹងស្តាប់ឲ្យមែនទែន តថាគតនឹងសំដែងប្រាប់ៈ ម្នាលយុវជន! សាវ័កតថាគតបានវៀរចាកមិច្ឆាជីវៈ ៤ យ៉ាងអស់មួយជីវិត មិនធ្វើនូវអំពើបាបដែលកើតមកអំពីអគតិ៤យ៉ាងអស់មួយជីវិត មិនប្រព្រឹត្ត អបាយមុខ ៦យ៉ាងដែលនាំឲ្យហិនហោចអស់ទ្រព្យសម្បត្តិ

អស់មួយជីវិត ។ សាវ័កតថាគតដែលបានលះបង់នូវអំពើអាក្រក់ ១៤យ៉ាងនេះឈ្មោះថា ជាអ្នកគោរពនូវទិសទាំង៦។

*ក) ដូចម្តេចហៅថា មិច្ឆាជីវៈ?* = ការមិនសំលាប់សត្វ, ការមិនលួចទ្រព្យគេ, ការមិនប្រព្រឹត្តខុសក្នុងកាមគឺខុសនឹងគន្លងធម៌លើប្រុតភរិយាអ្នកដទៃ,និងការមិនពោលពាក្យកុហក។

*ខ) ដូចម្តេចហៅថា ធ្វើអំពើបាបបណ្តាលមកពីអគតិ ៤ យ៉ាង?* គឺអំពើបានដែលកើតមកពីការស្រលាញ់រាប់អាន (ឆន្ទាគតិ), ការខឹងក្រោធ ស្អប់ (ទោសាគតិ), ការល្ងង់ខ្លៅ (មោហាគតិ), និងការភ័យខ្លាច(ភយាគតិ)។

*គ) ដូចម្តេចខ្លះហៅថា អបាយមុខ ៦ យ៉ាង?* = ការប្រព្រឹត្តល្បែងស្រាជានិច្ច, ការដើរលេងតាមទីច្រកល្ហកខុសកាលវេលា,ការប្រព្រឹត្តល្បែងស្រី,ការប្រព្រឹត្តល្បែងភ្នាល់គ្នា, ការសេពគប់មិត្តអាក្រក់និងការខ្ជិលច្រអូស។

= *ការប្រព្រឹត្តល្បែងស្រា រមែងមានទោស ៦ យ៉ាង:* ១. ហិនហោចទ្រព្យសម្បត្តិដែលមានហើយ, ២. បង្កើតការ ឈ្លោះវិវាទ, ៣. នាំឲ្យមានកើតរោគបានដោយងាយ, ៤. ខូចចរិយាសណ្តាប់ធ្នាប់, ៥. មិនមានការអៀនខ្មាស់ក្នុងការ លែងខ្លួន, ៦. នាំឲ្យខ្សោយប្រាជ្ញា ។

= *ការដើរលេងខុសពេលវេលា មានទោស ៦ យ៉ាង:* ១. នាំឲ្យមានអសន្តិសុខដល់ខ្លួន, ២. នាំឲ្យមានអសន្តិសុខដល់បុត្រភរិយា, ៣. នាំឲ្យមានអសន្តិសុខដល់ទ្រព្យសម្បត្តិ, ៤.នាំឲ្យគេង្ស័យថាជាមនុស្សប្រព្រឹត្តចោរកម្មជាដើម, ៥. ការចោទប្រកាន់ខុសបែបបទអាចធ្លាក់មកលើខ្លួន, ៦. នឹងមានគ្រោះថ្នាក់ដទៃទៀតជាច្រើនដែលត្រូវជួបប្រទះ។

= *ការប្រព្រឹត្តល្បែងស្រី មានទោស ៦យ៉ាង:* ១. នាំឲ្យគិតតែដើររករោងរាំ, ២. នាំឲ្យគិតតែដើររករោងចម្រៀង, ៣. នាំឲ្យគិតតែដើររករោងតន្ត្រី, ៤. នាំឲ្យគិតតែដើររករោងល្ខោន, ៥. នាំឲ្យគិតតែដើររករោងល្បែងឆាបឈ្មោះ,៦.នាំឲ្យគិតតែដើររករោងល្បែងស្គរឆៃយ៉ាំ។

= *ការប្រព្រឹត្តល្បែងភ្នាល់ មានទោស ៦ យ៉ាង:* ១. អ្នកឈ្នះតែងព្រួយបារម្ភចំពោះគំនុំចិត្តអ្នកចាញ់, ២. អ្នកចាញ់ នឹងស្តាយទ្រព្យរបស់ខ្លួនដែលចាញ់ទៅនោះ, ៣. ទ្រព្យសម្បត្តិដែលធ្លាប់មានមកហើយនោះនឹងវិនាសបាត់បង់ទៅវិញ, ៤. ពាក្យសំដីគ្មានតំលៃនៅក្នុងតុលាការ, ៥. ត្រូវមិត្តភក្តិនិងអ្នករាជការមើលងាយមើលថោក, ៦. មិនមាននរណាម្នាក់ចង់ទាក់ទងអោយកូនចៅមានគូរស្រករជាមួយព្រោះគេនិយាយថាមនុស្សល្បែងមិនអាចចិញ្ចឹមភរិយាខ្លួនបានឡើយ។

= *ការគប់បាបមិត្ត មានទោស ៦ យ៉ាង:* ១. អាចក្លាយទៅជាអ្នកល្បែង, ២. អាចក្លាយជាអ្នក

លេងស្រី, ៣. អាចក្លាយជាអ្នកប្រមឹក, ៤. អាចក្លាយជាអ្នកឆបោក, ៥. អាចក្លាយជាអ្នកលួចប្លន់, ៦. ជាមនុស្សមានមិត្តភក្តិច្រើនតែជាមនុស្សកំណាច។

= *មនុស្សទម្លាប់ខ្លួនអោយខ្ជិលច្រអូស មានទោស ៦ យ៉ាង:* មនុស្សនោះតែងនិយាយថា: ត្រជាក់ពេកធ្វើការមិន កើត,ក្តៅពេកធ្វើការមិនកើត,ព្រឹកពេកធ្វើការមិនកើត, យប់ពេកធ្វើការមិនកើត, ឃ្លានពេកធ្វើការមិនកើត, ឆ្អែតពេកធ្វើការមិនកើត ។ ម្លោះហើយកិច្ចការដែលត្រូវធ្វើប៉ុន្មានឥតបានធ្វើទាំងអស់ ។ ទ្រព្យសម្បត្តិថ្មីៗគ្មានចូលហើយទ្រព្យ សម្បត្តិដែលបានរកមកហើយត្រូវចាយវាយអស់។

**=មិត្តមិនគួរសេពគប់៤ពួក:**

*ក) មិត្តល្មោភប្រាក់កាស:* ចាយបន្តិចបន្តួចតែសំលឹងយកប្រយោជន៍ច្រើន, ធ្វើការអ្វីដោយសារសេចក្តីខ្លាចនិងគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន។
*ខ) មិត្តបានតែមាត់:* ដល់ពេលមានកិច្ចការពឹងពាក់ម្តងម្កាល ដោះដៃថាយ៉ាងនេះយ៉ាងនោះ ។
*គ)មិត្តចាក់បណ្តោយ:* យល់ស្របទាំងអស់ក្នុងការធ្វើអាក្រក់ហើយប្រឆាំងជានិច្ចក្នុងការធ្វើត្រូវសរសើរយើងតែនឹងមុខនិយាយដើមប្រាប់អ្នកដទៃពីក្រោយខ្នង។
*ឃ)មិត្តជួយបំផ្លាញ:* តាំងខ្លួនជាមិត្តរបស់យើងពេលណាយើងមានលុយស៊ីផឹក ពេលយើងដើរលេងខុសពេលតាមច្រកល្ហក ពេលយើងទៅមើលកុនល្ខោនឬទៅដើរលេងស្រីឬក៏ក្នុង ពេលដែលយើងកំពុងប្រព្រឹត្តល្បែងភ្នាល់។

**=មិត្តគួរគប់រកមាន៤ពួក:**

*ក) មិត្តឧបត្ថម្ភ:* ជួយថែទាំយើងក្នុងពេលដែលយើងគ្មានអ្នកថែទាំ, ជួយថែរក្សាសម្បត្តិយើងក្នុងពេលយើងមិន នៅ, ជាពំនឹងរបស់យើងក្នុងពេលដែលយើងមានភ័យ និងជួយរំលែកការងារដែលលំបាកៗបើត្រូវការពឹងពាក់។
*ខ) មិត្តរួមសុខរួមទុក្ខ:* ប្រាប់យើងនូវអាថិកំបាំងរបស់ខ្លួនគេ, បិទបាំងនូវអាថិកំបាំងរបស់យើងមិនបោះបង់យើងនៅពេលមានការលំបាកហ៊ានលះបង់សូម្បីជីវិតរបស់ខ្លួនចំពោះជីវិតរបស់យើង ។
*គ) មិត្តមគ្គុទេសក៍:* ហាមឃាត់យើងមិនអោយធ្វើអំពើខុស, រួបរួមជាមួយនឹងយើងក្នុងអំពើត្រូវ, ប្រាប់យើងនូវ រឿងរ៉ាវដែលយើងមិនដែលធ្លាប់បានឮ, បង្ហាញយើងនូវផ្លូវទៅរកសេចក្តីសុខ ។
*ឃ)សមានមិត្ត:* មិនត្រេកអរចំពោះគ្រោះថ្នាក់របស់យើង, រីករាយចំពោះការចំរុងចំរើនរបស់

យើង, ហាមឃាត់នរណាមួយដែលនិយាយអាក្រក់អំពីយើង, សរសើរបុគ្គលណាដែលនិយាយល្អពីយើង ។

ម្នាលយុវជន, មាតាបិតាទុកជាទិសខាងកើត, គ្រូបង្រៀនជាទិសខាងត្បូង, ភរិយានិងបុត្រធិតាទុកជាទិសខាងលិច, មិត្តសំលាញ់ទុកជាទិសខាងជើង, អ្នកបំរើនិងកម្មករ ជាទិសខាងក្រោម, គ្រូឧបជ្ឈាយ៍និងព្រាហ្មណ៍ជាទិសខាងលើ។

=*កូនគប្បីសង្គ្រោះមាតាបិតាដោយន័យ៥យ៉ាង:*

១. ត្រូវតែទំនុកបំរុងលោកវិញ ព្រោះលោកបានទំនុកបំរុងខ្លួនពីមុនមក,

២. ត្រូវតែជួយធ្វើការ សំរាលភារៈរបស់លោក,

៣. ត្រូវតែរក្សាទុកនូវវង្សត្រកូល និងប្រពៃណីរបស់គ្រួសារ,

៤. ត្រូវតែធ្វើខ្លួនអោយសមគួរ ល្មមជាអ្នកទទួលនូវកេមរតក,

៥. ពេលលោកធ្វើមរណកាលទៅ ធ្វើបុណ្យទានឧទ្ទិសកុសលជូនលោក,

= *ក្នុងន័យដូចគ្នា, មាតាបិតាគប្បីសង្គ្រោះបុត្រធីតា ដោយន័យ ៥ យ៉ាង:*

១. ហាមឃាត់កូនមិនឲ្យធ្វើអំពើអាក្រក់,

២. ណែនាំកូនឲ្យធ្វើតែអំពើល្អ,

៣. អប់រំកូនឲ្យមានការងាររមុខរបរសមរម្យ,

៤. រៀបចំអពាហ៍ពិពាហ៍ឲ្យកូន,

៥. ប្រគល់កេរមរតក តាមការគួរ,

= *សិស្សត្រូវឧបត្ថម្ភគ្រូដោយន័យ ៥ យ៉ាង:*

១. ដោយការក្រោកទទួល,

២. ធ្វើគារវកិច្ច,

៣. ចាំបំរើគ្រូ,

៤. យកចិត្តទុកដាក់ក្នុងការរៀនសូត្រ,

៥. ចាត់ចែងទឹកក្ដៅ ទឹកត្រជាក់ គក់ច្របាច់,

= *គ្រូគប្បីសង្គ្រោះសិស្សដោយន័យ ៥ យ៉ាង:*

១. ប្រៀនប្រដៅសិស្សដោយល្អ,

២. បង្រៀនសិស្សដោយល្អ,

៣. បង្រៀនសិស្សគ្រប់មុខវិជ្ជាដែលខ្លួនចេះ,

៤. ប្រកាសគុណសម្បត្តិរបស់សិស្សក្នុងកណ្ដាលទីប្រជុំ,

៥. រក្សាការពារសិស្សគ្រប់មធ្យោបាយទាំងអស់,

= *ស្វាមីគប្បីសង្គ្រោះភរិយាដោយន័យ ៥ យ៉ាង:*

១. ស្រលាញ់រាប់អានដ៏ស្មោះ

២. ពោលពាក្យទន់ភ្លន់ មិនមើលងាយមើលថោក

៣. មិនក្បត់ចិត្តភរិយា

៤. ប្រគល់តំណែងជាស្រីមេផ្ទះពេញលក្ខណ:

៥. ផ្ដល់គ្រឿងអលង្ការផ្សេងៗ តាមការគួរ

= *ភរិយាគប្បីសង្គ្រោះស្វាមី ដោយន័យ ៥ យ៉ាង:*

១. ចាត់ចែងធ្វើការគ្រប់យ៉ាងដោយផ្ចិតផ្ចង់,

២. រាប់អានញាតិខាងស្វាមី និងញាតិខាងខ្លួនដោយស្មោះស្មើ,

៣. ថែរក្សាទ្រព្យសម្បត្តិដែលស្វាមីរកមក ទុកឲ្យគង់វង្ស,

៤. មិនក្បត់ចិត្តស្វាមី,

៥. ប៉ិនប្រសប់និងប្រឹងប្រែងជានិច្ចធ្វើការគ្រប់យាងរបស់ខ្លួន,

= *នាយថៅហ្វាយ គប្បីសង្គ្រោះកម្មករ ដោយន័យ ៥ យ៉ាង:*

១. តម្រូវឲ្យធ្វើការងារតាមសមគួរដល់កម្លា,

២. ផ្តល់អាហារនិងតម្លៃឈ្នួលតាមគួរ,

៣. ជួយព្យាបាលក្នុងគ្រាមានជម្ងឺ,

៤. ចែករំលែកនូវវត្ថុចំលែក,

៥. អនុញ្ញាតច្បាប់សំរាក តាមការគួរ។

= *កម្មករ គប្បីសង្គ្រោះថៅហ្វាយនាយ ដោយន័យ ៥ យ៉ាង:*

១. ក្រោកពីដេកមុននាយថៅហ្វាយ,

២. ប្រកបការងារមុនថៅហ្វាយនាយ,

៣. រីករាយទទួលតែវត្ថុអ្វីដែលថៅហ្វាយអោយ,

៤. ធ្វើការរបស់ខ្លួនដោយយកចិត្តទុកដាក់,

៥. និយាយសរសើរកិត្តិគុណរបស់ថៅហ្វាយក្នុងទីទាំងពួង,

សិគាលោវាទសូត្រនេះ មាននៅក្នុងគម្ពីរទីឃនិកាយ ជាសូត្រខ្លីៗតែងាយយល់ ជាសូត្រស្តីពីការរស់នៅដ៏ប្រសើរនៅក្នុងសង្គមមនុស្ស ។
សូត្រនេះមានន័យនិងគុណប្រសើរវិសេសសំរាប់មនុស្សទូទៅ ហើយអាចយកអនុវត្តបានគ្រប់

កាលៈ ទេសៈទាំងអស់ ។ ប្រពៃណីនិងការរស់នៅរបស់មនុស្សតែងប្រែប្រួលពីសតវត្សមួយទៅសតវត្សមួយ តែគោលធម៌ សំខាន់ៗនៃចរិយាត្រូវនិងខុសពុំប្រែប្រួលឡើយ ។ ឱវាទដ៏ប្រសើរនេះនៅតែមានសេចក្ដីពិតរស់រវើកគ្រប់ពេលវេលាទាំងអស់ចំពោះមនុស្សទូទៅ។ សិគាលោវាទសូត្រនេះទាក់ទងនឹងសង្គមមនុស្សទាំងស្រុង។

ព្រះឱវាទរបស់ព្រះអង្គក្នុងសូត្រនេះ ងាយស្ដាប់ងាយយល់ ហើយមានភាពពិតឥតល្អៀងផងពីទិដ្ឋភាពគ្រប់យ៉ាងនៃជីវិតប្រចាំថ្ងៃរបស់មនុស្សទូទៅ។ ត្រង់នេះបញ្ជាក់ឲ្យឃើញថាព្រះពុទ្ធព្រះអង្គស្គាល់ច្បាស់នូវជីវិតរបស់មនុស្ស,ជាអ្នក ប្រាកដនិយម មានព្រះទ័យពោរពេញដោយមេត្តានិងករុណាជាកល្យាណមិត្តរបស់មនុស្សទាំងអស់។

បញ្ហាគ្រប់យ៉ាងនៃមនុស្សលោក អាចរលុបរលាយសាបសូន្យទៅបានប្រសិនបើពិភពលោកសិក្សាក្នុងសូត្រនេះហើយប្រតិបត្តិតាមដោយម៉ត់ចត់។ សិគាលោវាទសូត្រនេះជាធម៌សំរាប់ដោះស្រាយបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ចនិងបញ្ហាសីលធម៌។

សិគាលោវាទសូត្រនេះប្រសើរដាច់គេក្នុងចំណោមវណ្ណកម្មផ្សេងៗខាងសាសនាក្នុងពិភពលោក ។ សូត្រនេះគ្មានលាយឡំនឹងទិដ្ឋិ(ជំនឿផ្សេង) ឬបរមត្ថវិជ្ជាអាថ៌កំបាំងឡើយព្រោះឱវាទក្នុងសូត្រនេះមានន័យភ្លឺច្បាស់លាស់បំផុត ប្រៀបដូចជាដុំត្បូងដែលគេបានច្នៃហើយយ៉ាងបរិសុទ្ធ ។ សូត្រនេះជាពុទ្ធវចនៈផ្ទាល់ដែលព្រះអង្គបានសំដែងប្រាប់ដល់មនុស្សក្នុងពិភពលោកទាំងមូល៕

*ប្រមូលរៀបរៀងដោយម៉ែន ប្រាង,អាំ ឆន, ពិនិត្យនិងកែសំរួលដោយលោក ឱម ខែម*

---

ដកស្រង់ចេញពី

*កម្ពុជសុរិយា*

*ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ*

*ឆ្នាំទី ៤៨ លេខ១ ព.ស ២៥៣៧, គ.ស ១៩៩៤*

ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម

www.bodhikaram.com